# ខ្មែរប៉ុស្តិ៍

ភ្នំខាងកើត

THE KHMER POST

EAST COAST

The Cambodian-American Biweekly News

Email : Khmerpostusa@gmail.com

Call : (267) 253-3947

VOLUME 04 ISSUE 58 April 23th - 06th May, 2010





●សូមប្រសិទ្ធពរបវរមហាប្រសើរជូនបងប្អូនជនរួមជាតិទាំងអស់ឱ្យប្រកបតែ (តទៅទំព័រ០៩)

វិចារណកថា

# ថ្ងៃ ១៧ មេសា ១៩៧៥

**ដោយ : ពិន សំខុន**

•••សាមសិបប្រាំក្រោយពីជោគជ័យនៃក្រុមខ្មែរក្រហមនិស្តកម្ពុជាប្រជាធិបតេយ្យលើក្រុមសាធារណរដ្ឋខ្មែរ នាថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរជាទូទៅរួមទាំងបរទេសដែលតាមដានព្រឹត្តិការណ៍កម្ពុជា នៅតែពុំទាន់ដឹងការពិតថា ហេតុអ្វីបានជាមានការគាប់សម្លាប់លើប្រជាពលរដ្ឋខ្មែរច្រើនអ្វីម្លេះ?

ខ្ញុំបានតាំងសំនួរចំពោះមេដឹកនាំកម្ពុជាប្រជាធិប-តេយ្យនៅតំបន់អប្បគមន៍អន្លង់វែង នាឆ្នាំ១៩៩៨ តាម៉ុក និង ខៀវ សំផន បានសម្តែងការភ្ញាក់ផ្អើលថា "កាលឯងនៅកាន់អំណាចគ្មានដែលឃើញខ្មោចណាមួយសោះដល់ឯងបាត់បង់កម្ពុជាទៅហើយ ស្រាប់តែឮថា មានជង្រុកអន្លុងគប់មនុស្ស ដែលត្រូវគេសម្លាប់រាប់លាននាក់ពីក្រោយខ្នង" ។ ខ្ញុំបានតាំងសំនួរទៅប៉ុល ពត ដែលជាមេដឹកនាំអង្គការលើផ្ទាល់ដែក៏បដិសេធដាច់អហង្កាថា "ខ្ញុំមកជួយស្រោចស្រង់ជាតិ ពុំមែនមកសម្លាប់ខ្មែរគ្នាឯងទេ ហើយម្យ៉ាងទៀត ខ្ញុំពុំដែលបានបញ្ជាឱ្យសម្លាប់នរណាទេ ពីព្រោះពុំមែនជាតួនាទីរបស់ខ្ញុំ ខ្ញុំគឺជាអ្នកដល់កម្មាភិបាលប៉ុណ្ណោះ" ។ ខ្ញុំបានជួប នួន ជា ក្រោយមកទៀត នៅប៉ៃលិន នាឆ្នាំ ២០០០ ក៏បានឆ្លើយនឹងសំនួរខ្ញុំដូចគ្នា ហើយថែមទាំងចង្អុលឱ្យតម្រុយថា "ឥឡូវទឹកល្អ គេមើលមិនឃើញថា នរណាជាឃាតករបន្តិចទៀតទឹកនឹងថ្លា ពិភពលោកនឹងឃើញច្បាស់ថា នរណាពិតប្រាកដដែលនៅពីក្រោយការសម្លាប់រង្គាលនោះ"។

សាមសិបប្រាំឆ្នាំក្រោយពីជ័យជំនះនៃមហាលោតផ្លោះនោះ តុលាការអន្តរជាតិបានបង្កើតឡើង ដោយអង្គការសហប្រជាជាតិ ដើម្បីវែកមុខអ្នកដែលទទួលខុសត្រូវពិតប្រាកដក្នុងការដែលបណ្តាលឱ្យពលរដ្ឋខ្មែរ តែមកទល់នឹងថ្ងៃនេះ តុលាការអន្តរជាតិនោះបានត្រូវគេឃើញថា ពុំមានសេរីភាពគ្រប់គ្រាន់ និងបង្ហាញស្មាដៃយុត្តិធម៌របស់ខ្លួននោះទេ ។ រដ្ឋាភិបាលនៃលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន នៅបង្ហាញសហការណ៍ជាមួយតុលាការនោះយ៉ាងទើសទាល់ជាទីបំផុត ។

(តទៅទំព័រទី ១២)









# ចូលឆ្នាំខាល នៅសមាគមខ្មែរ ប្រចាំហ្វីឡាដែលហ្វៀ



ដោយ : ឡានិកា

•••ភ្ញៀវប្រមាណ ៥០០ នាក់ បានអញ្ជើញមកចូលរួមពិធីទទួលឆ្នាំថ្មី កាលពីថ្ងៃទី១០ ខែមេសា ឆ្នាំ ២០១០ រៀបចំដោយសមាគមខ្មែរ ដែលបានសំរាំងការទទួលភ្ញៀវបានយ៉ាងគួរឱ្យចាប់អារម្មណ៍

The entry way was lined with red ropes and valet waited to park guests' cars. The Cambodian Association of Greater Philadelphia (CAGP) was beginning their celebration of Khmer New Year at the Regal Ballroom on Oxford Avenue in North Philadelphia. Guests were greeted at the front desk by CAGP's staff and volunteers, and served a buffet style dinner. Special

CAGP and how CAGP is currently helping those in the community presently. The video was entitled "The CAGP Story," and was made and edited by Vimul Ros and Sarun Chan (of Amara Philly Magazine). The dances performed, respectively, were: Robaim Joun Por (The Wishing Dance), Robaim Tivea Propei (Glorious Day Dance), and Robaim Neary Chea Chour (Beautiful Girl Line Dance). Each of the dances included all of the students from CAGP's Sunday dance classes.

At the end of the night, before the actual

ly seen during the celebration of Cambodian New Year. The only two boys, Kimsath Yin and Manny Son, in the dance showed the men how to "move it," and the ladies (Dyliyah Heng, Cynthia Son, Sarah Noun, Kristine Thach, Linda Son, Trucly Thach, and I) showed the ladies how to "work it."

Over all, the night was splendid. Although the celebration was cut short due to an accident taken place, CAGP was really able to pull off a wonderful new year's celebration. My best wishes to the family affected by the accident.



Michael Nutter



Dr. Evan សញ្ញាប្រញ


នាថការីរាំរបាំងជូនពរភ្ញៀវ

ភ្ញៀវពិសេសនាឆ្នាំនេះ បានអញ្ជើញមកយ៉ាងអ៊ូអរ មានចៅហ្វាយក្រុង Michael Nutter នាយកអង្គការ DBH, Dr. Evan នាយកក្រសួងអប់រំ Ms Ackman ហើយមានទាំងតំណាងព្រឹទ្ធសមាជិក Kitchen... ចូលរួមផងដែរ ។ ឡានិកា ជានាថការី ដ៏ឆ្នើមម្នាក់ នារាត្រីសមោសរនោះ បានសរសេររៀបរាប់ពីព្រឹត្តិការណ៍នៃការជួបជុំសហគមន៍ខ្មែរយ៉ាងនេះថា

guests included Philadelphia's Mayor Michael Nutter and Dr. Evans, a longtime supporter of CAGP. The night was hosted by Mr. Bunrath Math and Mrs. Nary Kith, the masters of ceremonies. Ending remarks, thanking everyone who attended, were made of executive director, Rorng Sorn.

Entertainment for the night included the live band "The Golden Eagle," and CAGP's culture program provided classical Cambodian dance performances. There was also a video, documenting the start of

dancing started for the guests, they were treated to a fashion show and social dance performance. The fashion show, which featured many volunteers , workers and students from CAGP, provided the guests with a view of what traditional Cambodian outfits are worn during the new year celebration. Immediately after the fashion show, nine students from CAGP's culture program started their social dance performance. The performance was a mixture of all different types of social dances common-

Special thanks to Koeun Chea and Putery Long for all of their efforts into making CAGP's New Year celebration bigger and better.

Thank you to the Cambodian Association for another wonderful celebration of Cambodian New Year. Thank you especially to the readers and supports of the Khmer Post (East Coast). Best wishes, health and prosperity to all.

# ចូលឆ្នាំខាល ព.ស ២៥៥៤



ដោយ : ដាណាលី

•••ចូលឆ្នាំខាល ឆ្នាំ ២៥៥៤ នេះ សហគមន៍ខ្មែរទៅធ្វើបុណ្យយ៉ាងកកកុញ ដូចសព្វមួយដង ។ ដាណាលី បានទៅចូលរួមនាឱកាសចូលឆ្នាំថ្ងៃសៅរ៍ និងថ្ងៃអាទិត្យកន្លងទៅនេះ នៅវត្តព្រះពុទ្ធវង្ស ស្ថិតនៅផ្លូវលេខ ៦ ខាងត្បូង ហើយធ្វើសេចក្តីរាយការណ៍ដូចតទៅជាភាសាអង់គ្លេស :

Danaly Sam
The Khmer Post Newspaper

PHILADELPHIA - The 2010 year of the tiger was celebrated at Cambodian temples that were in the Northern, Southern, and Southwestern regions of Philadelphia over the weekend of April 17 and April 18.

At the Cambodian Buddhist temple at 6th and Ritner Streets of South Philadelphia, the celebration began with people of all ages who stood at the 6th Street entrance of the temple. A vast amount of people began to descend into the temple, where nearly all of the women wore the traditional Khmer attire that consisted of long folded skirts and crocheted shirts, and button down shirts and slacks for the men. Many young girls were dressed in dresses and boys had an appearance like the men, except that they were jovial, smiling, and running around.

Saturday's celebration of the New Year then transitioned into people sitting on the "krathel" (plastic rugs with colorful designs of flowers and birds) where people's legs were folded neatly to their sides, and their arms raised in prayer with the chanting of the monks.

The monks chanted verses of blessings and thanks for the New Year that has gone and come, while people descended onto the raised platform, where the monks sat, overseeing about 200 attendees of the religious festival.





People gave gifts of thanks to the monks that primarily consisted of food and money that is to help with the everyday operations of the temple. The monks then gave words of blessings to the givers as the people prayed along with him, with their hands raised before them.

The voices of the monks surrounded throughout the room with the help of the standing speakers that sat in three corners of the large room.

Once the monks were finished eating their food that was devoted to them by the attendants of the day's ceremony in a process known as "chan" in Khmer, the food was then brought to the attendants.

Circles of families sat on the floors of the temple. They huddled close together as they smiled and laughed while they enjoyed the varieties of Khmer delicacies that they brought or was made by the helpers of the temple.

There were numerous activities that waited outside of the temple. This included song-and-dance with a live band who sang at the front entrance of the temple on Ritner Street, traditional Khmer games that included hitting a clay pot that was filled with money blind-folded with a stick, and racing on foot in a potato sack by gender.

There were vendors who sold all types of foods at the park across the street. There were varieties of foods such as the barbecued chicken and beef-on-a-stick, eggrolls, spicy papaya salad also known as "bok-lahong," which literally means mashing papaya, and many other Khmer delicacies.







The Cambodian celebration of the New Year is celebrated all over the world wherever there maybe Cambodians who either live abroad or in Cambodia. The celebration spanned about three days that began since April 14 to mark the end of the harvesting season and the beginning of the rainy season.

# កិច្ចសម្ភាសន៍រវាងខ្មែរប៉ុស្តិ៍ជាមួយប្រធានគណបក្សសិទ្ធិមនុស្ស

(តមកពីលេខមុន)

ដោយ : អ៊ឹម លឿម

•នេះជាគ្រោះថ្នាក់មួយដ៏ធំណាស់ ដែលយើងមើលឃើញថា រីកមែន រីកផ្លូវ រីកថ្នល់ ប៉ុន្តែបើថ្ងៃណាមួយយួនដែលគេបានដីស្រុកខ្មែរ ហើយនុះ ១០ម៉ឺនហិចតា ប៉ុន្តែគេសុំ៤៥ម៉ឺនហិចតា, ផែនការណ៍គេគឺ ៤៥ម៉ឺនហិចតា, ចុះបើសិនជាប្រជាជនគេមករស់នៅដាំកៅស៊ូហ្នឹង កើតកូនកើតចៅហ្នឹងទៅរាប់លាននាក់ តើថ្ងៃក្រោយទៅយើងដោះស្រាយបញ្ហាហ្នឹងបានទេ អភិវឌ្ឍន៍សម្រាប់អ្នកណា ។ អ្វីដែលខ្ញុំព្រួយបារម្ភខ្លាំង គឺរឿងអធិបតេយ្យភាព បូរណភាពទឹកដី ។ រឿងព្រំដែនជារឿងមួយដែរ ប៉ុន្តែរឿងអន្តោប្រវេសន៍ ដែលហូរចូលខុសច្បាប់ស្រេចចិត្តនោះ ជាពិសេស យួនដែលចូលស្រេចចិត្តនេះ វាជារឿងមួយដែលគ្រោះថ្នាក់សម្រាប់ប្រទេសជាតិយើង ហើយជាផែនការណ៍របស់យួនដែលយើងដឹងហើយថា យួនគេមកដល់ថ្ងៃនេះ គឺគេសម្រេចនូវជោគជ័យរបស់គេហើយ គេកំពុងប្រមូលជ័យភ័ណ្ឌ, កាលគេចូលមកស្រុកខ្មែរ សម័យទសវត្សរ៍ ៤០, សម័យហ្នឹងគេមកជាយៀកមិញ គេមិនទាន់បានទទួលអីពីយើងទេ បានបរាជ័យទៅវិញ ។ សម័យយៀកកុង ក៏គេមិនទាន់បានទទួល ប៉ុន្តែមកដល់សម័យ ៧ មករា គឺជាភាពជោគជ័យ សម្រេចចុងក្រោយរបស់គេហើយ ហ្នឹងគឺជាគ្រោះថ្នាក់ធំ ដែលខ្ញុំគួរព្រួយបារម្ភ។ គ្រោះថ្នាក់ធំទី២ ដែលខ្ញុំចាប់អារម្មណ៍ គឺលទ្ធិប្រជាធិបតេយ្យ ដែលយើងទាំងអស់គ្នាសង្ឃឹមថា ក្រោមកិច្ចព្រមព្រៀងក្រុងប៉ារីស ឆ្នាំ១៩៩១មក ថាយើងកសាងប្រទេសយើងឱ្យទៅជាប្រទេសប្រជាធិបតេយ្យសេរីពហុបក្ស យើងមានការបោះឆ្នោតឆ្នាំ១៩៩៣ ប៉ុន្តែទីបញ្ចប់ មកដល់អាណត្តិទីបួននេះ បក្សប្រជាជនបានឈ្នះដាច់ គឺបានដល់ទៅ៩០កៅអី គឺគេបានជិះសេះលែងដៃ, កាលណាជិះសេះលែងដៃហើយ គឺអស់និយាយពីប្រជាធិបតេយ្យហើយ ។ តុលាការក៏នៅក្នុងដៃបក្សប្រជាជន, សភាក៏នៅលើដៃបក្សប្រជាជន, តុលាការចង់ចាប់នរណាក៏បានដែរ, ទាំងនេះហើយជាគ្រោះថ្នាក់ដែលខ្ញុំចាប់អារម្មណ៍ ។

អ៊ឹម លឿម : បាទសូមអរគុណឯកឧត្តម ! ចំពោះសំនួរដោយឡែកទៀត ដែលពលរដ្ឋខ្មែរគ្រប់ច្រកល្ហកទាំងអស់ចង់ឃើញ និងចង់បានអំពីការរួបរួមគ្នារវាងអ្នកប្រជាធិបតេយ្យ ដែលមានគណបក្ស សម រង្ស៊ី និងគណបក្សសិទ្ធិមនុស្ស តើរហូតមកដល់ពេលនេះ មានការវិវឌ្ឍន៍ដល់ណាហើយ ?

កឹម សុខា : ខ្ញុំសូមជម្រាបថា គណបក្សសិទ្ធិមនុស្សបានសម្រេចចិត្តជាស្រេចហើយ មិនមែន កឹម សុខា ប្រធានបក្សជាអ្នកសម្រេចទេ គឺអង្គសន្និបាតរបស់គណបក្សបានសម្រេចថា គណបក្សសិទ្ធិមនុស្សត្រូវរួមជាមួយគណបក្ស សម រង្ស៊ី ឱ្យបាននៅឆ្នាំ ២០១២-២០១៣ នេះ ដោយមានបញ្ជីបោះឆ្នោតតែមួយ ។ យើងរង់ចាំតែគណបក្ស សម រង្ស៊ី ឆ្លើយតបដើម្បីធ្វើយន្តការជាមួយគ្នា ក្នុងការរួបរួមរបៀបម៉េច, ធ្វើបញ្ជីរបៀបម៉េច, គោលការណ៍របៀបម៉េច គឺយើងរង់ចាំចម្លើយពីគណបក្ស សម រង្ស៊ី ប៉ុន្តែរហូតមកដល់ពេលនេះ គណបក្ស សម រង្ស៊ី មិនទាន់បានឆ្លើយជាផ្លូវការ



លោក កឹម សុខា ប្រធានគណបក្សសិទ្ធិមនុស្ស

ទោះបីជាយើងខិតខំ ទំនាក់ទំនងយ៉ាងណា ក៏ដោយក៏អត់បាន ឆ្លើយទេ ប៉ុន្តែគណបក្ស សិទ្ធិមនុស្សមិនដេកចាំលោក សម រង្ស៊ី ឬគណបក្ស សម រង្ស៊ី ទេ ។ គណបក្សសិទ្ធិមនុស្ស គឺធ្វើការងាររួបរួមនេះបន្តគឺបើកទ្វារបន្តសម្រាប់ឆ្នាំ២០១០នេះ ។ ក្រៅពីគណបក្ស សម រង្ស៊ី យើងមានឥស្សរៈជន នយោបាយអ្នកប្រជាធិបតេយ្យជាច្រើនទៀត កំពុងតែជជែកជាមួយយើង មានគណបក្សច្រើនទៀត ជាពិសេស លោក ម៉ម សុណង់ដូ ដែលជាអ្នកល្បីនៅ ស្រុកខ្មែរដែរ, ជាអ្នកក្លាហាន, អ្នកគិតពីប្រយោជន៍ជាមួយដែរ គឺកំពុងតែធ្វើជាមួយគណបក្សសិទ្ធិមនុស្សយ៉ាងជិតស្និទ្ធ ។ ហើយក្រៅពីនោះទៀត ទោះបីជានយោបាយរបស់គណបក្ស សម រង្ស៊ី មិនទាន់ឆ្លើយក្នុងការរួបរួមនេះក៏ដោយ ក៏សមាជិក សម រង្ស៊ី នៅតាមមូលដ្ឋាន បានមករួមប្រាស្រ័យទាក់ទងធ្វើការជាមួយគណបក្សសិទ្ធិមនុស្សនៅមូលដ្ឋានរួចជាស្រេចហើយ ។

អ៊ឹម លឿម : ក្នុងកាលៈទេសៈដែលលោក សម រង្ស៊ី កំពុងមានទោសទ័ណ្ឌ រហូតឈានដល់ការជាប់ពន្ធនាគារ បើសិនណាគាត់ឈានជើងចូលមកប្រទេសកម្ពុជា ក្នុងនាមជាដៃគូរសម្ព័ន្ធអ្នកប្រជាធិបតេយ្យ ដើម្បីការផ្លាស់ប្តូរ តើគណបក្សសិទ្ធិមនុស្ស មានការអន្តរាគមន៍ ឬវិធីសាស្ត្រណាមួយ ដើម្បីឱ្យគណបក្ស សម រង្ស៊ី វិលចូលស្រុកវិញបាន ដោយគ្មានទោសទ័ណ្ឌនោះបាទ ?

កឹម សុខា : យើងដឹងថា គណបក្សសិទ្ធិមនុស្សហើយខ្លួនខ្ញុំផ្ទាល់ គឺគាំទ្រគោលការណ៍ប្រជាធិបតេយ្យ, គាំទ្រគោលការណ៍ច្បាប់, គាំទ្រនូវឧត្តមគតិជាតិនិយម, ដូច្នេះ យើងគាំទ្រនូវទង្វើរបស់គាត់, នូវសកម្មភាពរបស់គាត់ក្នុងនាមជាដៃគូរ ហើយយើងក៏តែងតែធ្វើសេចក្តីថ្លែងការណ៍រួមគ្នាជាមួយគណបក្ស សម រង្ស៊ី ដើម្បីប្រឆាំងនឹងការដែលប្តឹងដល់គាត់, ការដែលកាត់ទោសគាត់ គឺយើងរួមយោបល់ជាមួយគ្នា ហើយយើងនៅជាមួយគ្នាជានិច្ចក្នុងការការពារអធិបតេយ្យភាពបូរណភាពទឹកដី ។

អ៊ឹម លឿម : ក្នុងដំណើរបេសកកម្មទៅកាន់អឺរ៉ុប តើឯកឧត្តមមានបំណងចង់ជួបលោក សម រង្ស៊ី ដោយមុខទល់នឹងមុខនៅឯប្រទេសបារាំង ដើម្បីពិភាក្សាពីការច្របាច់បញ្ចូលគ្នារវាងគណបក្សទាំងពីរដែរទេបាទ ?

កឹម សុខា : ខ្ញុំមានបំណង ប៉ុន្តែមិនដឹងលោក សម រង្ស៊ី មានបំណងដែរឬអត់, ធម្មតាទះដៃមួយចំហៀងមិនឮទេ ហើយមិនសិនជាលោក សម រង្ស៊ី

(តទៅទំព័រទី ១៦)

# សម រង្ស៊ី ស្វែងរកឃើញឯកសារពិតពីរឿងព្រំដែនខ្មែរ_យួន ?

(តពីលេខមុន)

•••ហើយគេប្រើវិទ្យាសាស្ត្រ គេប្រើបច្ចេកទេសថ្មីៗដូចជារូបភាពដែលបានមកពីផ្កាយរណប ពីព្រោះនៅដែនអាកាសហ្នឹងមានផ្កាយរណបច្រើនណាស់ ដែលមានម៉ាស៊ីនថតខ្លាំង ហើយថតឃើញទិដ្ឋភាពច្បាស់នៅលើផែនដីយ៉ាងម៉េច ហើយគេមានបច្ចេកទេសដើម្បីពង្រីករូបថតហ្នឹងឱ្យបានធំ ហើយមើលពីលើមេឃមកអាចឃើញផ្លូវថ្នល់ អាចឃើញផ្ទះសម្បែង ។ ដូច្នេះយើងពង្រីកមក យើងឃើញច្បាស់ថា ទិដ្ឋភាពនៅកន្លែងនោះ ជាពិសេស នៅតាមព្រំប្រទល់ដែននោះរូបភាពមានលក្ខណៈយ៉ាងម៉េច **ទី1** ។ **ទី2** មានកុំព្យូទ័រប្រើសម្រាប់គិតគូរ ទោះជាតួលេខច្រើនពិបាកយ៉ាងម៉េច ស្មុគស្មាញយ៉ាងម៉េច តែកុំព្យូទ័រដោយមានកម្មវិធីពិសេសរបស់វាដែលគេ បានរៀបចំដែលគេបានផលិតតាមបច្ចេកទេសភូមិសាស្ត្រ បច្ចេកទេសខាងធ្វើផែនទីមានប្រព័ន្ធវាស់វែងច្រើនណាស់ដែលខ្ញុំមិនចាំបាច់លំអិតទេ ។ អ្វីដែលមនុស្សយើងគិតខ្លួនឯង យកក្បាលថៃមកគិតខ្លួនឯង អាហ្នឹងយូរណាស់ ជួនកាលអាចគិតច្រឡំទៀត ។ ប៉ុន្តែបើយើងប្រើកុំព្យូទ័រ ប្រើប្រព័ន្ធពិសេសរបស់កុំព្យូទ័រ នោះយើងនឹងឃើញលទ្ធផលជាក់ស្តែងដែលពីដើមវាស្មុគស្មាញយ៉ាងម៉េច តែឥឡូវមិនស្មុគស្មាញទេ លទ្ធផល គឺវាច្បាស់ដែលមិនអាចប្រកែកបាន ។ ដូច្នេះយើងបូកបញ្ចូលបច្ចេកទេសទាំងអស់ហ្នឹងទៅ យើងរៀបចំទៅឃើញយ៉ាងច្បាស់ឃើញកន្លែងដែលខ្ញុំដកបង្គោលនោះមានឃើញវត្ត ឃើញផ្លូវថ្នល់ ឃើញដីស្រែប្រជាពលរដ្ឋ ឃើញខាងខ្មែរផង និងឃើញខាងយួនផង ។ ចំណុចដែលខ្ញុំដកបង្គោលព្រំដែន គឺច្បាស់នៅខាងខ្មែរក្នុងទឹកដីខ្មែរទេបាទ ! ។ សូម្បីតែប្រទេសយួនក៏គេទទួលស្គាល់ដែរ ពីព្រោះប្រទេសយួនរដ្ឋាភិបាលគេក៏ប្រើផែនទីប្រទេសបារាំងដែលខ្ញុំយកមកធ្វើជាមូលដ្ឋាននៃការស្រាវជ្រាវនេះដែរបាទ ! ។

**មាជ សុវណ្ណារ៉ា :** លោក សម រង្ស៊ី បាទ ! ចុះការចោទប្រកាន់របស់តុលាការក្រុងភ្នំពេញ ពីការថាលោកប្រធានប្រើប្រាស់ឯកសារក្លែងក្លាយ តើលោកយល់យ៉ាងណាដែរពីបញ្ហាហ្នឹងបាទ ! ?

**សម រង្ស៊ី :** ខ្ញុំមិនយកទៅឱ្យតុលាការនៅក្រុងភ្នំពេញនោះទេ ពីព្រោះតុលាការហ្នឹង ជាតុលាការអាយ៉ង តុលាការលេងសើច ខ្ញុំមិនទៅលេងសើចជាមួយតុលាការហ្នឹងទេ ពីព្រោះរឿងនេះមិនមែនជារឿងតុលាការទេ រឿងនេះជារឿងប្រទេសជាតិរបស់ខ្មែរយើងទាំងអស់គ្នា រឿងនេះជារឿងដែលមានសារសំខាន់សម្រាប់មាតុភូមិយើង ពីព្រោះទឹកដីប្រទេសកម្ពុជាជាទឹកដីរបស់ខ្មែរទាំងអស់គ្នា ជាទឹកដីរបស់ប្រជារាស្ត្រខ្មែរ ។ ដូច្នេះខ្ញុំនឹងយកភស្តុតាងហ្នឹងទៅលាតត្រដាងជូនប្រជារាស្ត្រខ្មែរតាមមធ្យោបាយផ្សេងៗទាំងអស់យើងនឹងបោះពុម្ពចែកឯកសារនេះជូនប្រជារាស្ត្រខ្មែរនៅឯប្រទេសកម្ពុជាយើងនឹងផ្សព្វផ្សាយតាមកម្មវិធីវិទ្យុដែលនឹងជួយផ្សព្វផ្សាយផងដែរ ពីព្រោះយើងត្រូវតែលើកតម្កើងការពិតការពិតហ្នឹងទេដែលយើងបាននិយាយពីដើមទីដែលអាចផ្តល់យុត្តិធម៌ និងអាចផ្តល់យុត្តិធម៌ជូនប្រទេសកម្ពុជាយើងទៀតផង ជូនប្រជាកសិករខ្មែរ ដែលបាត់បង់ដីធ្លី បាត់បង់ដីស្រែនៅតាមព្រំប្រទល់ដែនផងបាទ! ។



**មាជ សុវណ្ណារ៉ា :** សំណួរចុងក្រោយនេះ ខ្ញុំបាទចង់សួរថា នៅពេលដែលលោកប្រធានចេញផ្សាយនូវឯកសារ តើមានការបារម្ភដល់ការចោទប្រកាន់ជាថ្មីបន្ថែមទៀតទេពីសំណាក់រដ្ឋាភិបាលលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន នោះ បាទ ! ?

**សម រង្ស៊ី :** ខ្ញុំមិនរវល់ទេ ខ្ញុំគ្រាន់តែកត់សម្គាល់ឃើញថា រដ្ឋាភិបាលអាជ្ញាធរនៅប្រទេសកម្ពុជាសព្វថ្ងៃអ្នកដឹកនាំប្រទេសហ្នឹង គឺច្បាស់ជាព្រួយបារម្ភហើយ ពីព្រោះចាប់ផ្តើមនិយាយផ្សព្វផ្សាយឱ្យឃើញថាទាំងអស់នេះ កំពុងតែមានការព្រួយបារម្ភ គឺមិនអាចទុកការពិតបានទេ។ យើងមិនអាចយកបាតដៃយើងទៅបិទកុំឱ្យឃើញព្រះអាទិត្យទេ សច្ចៈធម៌ការពិតដូចជាពន្លឺព្រះអាទិត្យ តើរដ្ឋាភិបាលមានលទ្ធភាពមានមធ្យោបាយអ្វីទៅបិទបាំងព្រះអាទិត្យបាន ។ ពន្លឺនៃការពិតហ្នឹង គឺត្រូវផ្សព្វផ្សាយឱ្យគេដឹងឮទាំងអស់គ្នាហើយ ពេលហ្នឹងការចោទប្រកាន់ពីសំណាក់រដ្ឋាភិបាលមកលើរូបខ្ញុំ សម រង្ស៊ី ការចោទប្រកាន់ គឺធ្លាក់មកលើខ្លួនឯងហើយ ។ ហើយអ្នកដែលប្រជារាស្ត្រខ្មែរវិញ គឺរដ្ឋាភិបាលសព្វថ្ងៃហ្នឹង រដ្ឋាភិបាលដែលបណ្តោយឱ្យបរទេសឈ្លានពានលេបត្របាក់ទឹកដីប្រទេសកម្ពុជា រដ្ឋាភិបាលសព្វថ្ងៃនឹងក្លាយខ្លួនជាអ្នកជាប់ចោទទៅវិញ គឺប្រជារាស្ត្រនឹងចោទយ៉ាងត្រឹមត្រូវថា រដ្ឋាភិបាលសព្វថ្ងៃមិនមែនប្រើផលប្រយោជន៍ខ្មែរទេ គឺបម្រើផលប្រយោជន៍ឱ្យបរទេស។ ពេលហ្នឹងសូមឱ្យជនជាតិខ្មែរ យើងទាំងអស់ធ្វើសេចក្តីសន្និដ្ឋានក្នុងចិត្តយើងទៅ ហើយគង់តែពេលវេលាមកដល់យើងត្រូវតែផ្តន្ទាទោសតាមរយៈសន្លឹកឆ្នោត ឬតាមរយៈមធ្យោបាយផ្សេងទៀត ។ ផ្តន្ទាទោសអ្នកដឹកនាំប្រទេសយើងសព្វថ្ងៃនេះដែលមិនបម្រើផលប្រយោជន៍ខ្មែរ តែបែរទៅបម្រើផលប្រយោជន៍ឱ្យបរទេសឈ្លានពានទៅវិញ ។

**មាជ សុវណ្ណារ៉ា :** បាទ ! ក្នុងនាមកាសែតខ្មែរប៉ុស្តិ៍ ខ្ញុំបាទសូមអរគុណលោកប្រធានគណបក្ស សម រង្ស៊ី ដែលផ្តល់ និងការអនុញ្ញាតឱ្យកាសែតខ្មែរប៉ុស្តិ៍ធ្វើកិច្ចសម្ភាសន៍ទាក់ទងទៅនឹងការដែលលោកប្រធានអះ-អាង ថានឹងមានឯកសារពិតប្រាកដស្តីអំពីបូរណភាពទឹកដីរវាងប្រទេសយួន និងខ្មែរ បាទ ! ។ ថាតើការអះអាងរបស់រដ្ឋាភិបាលថាលោកបង្ហាញផែនទីក្លែងក្លាយឯកសារក្លែងក្លាយ ហើយលោកក៏បានចោទប្រកាន់វិញថា លោក វ៉ា គឹមហុង ក៏ដូចជារដ្ឋាភិបាលលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានធ្វើនូវផែនទីក្លែងក្លាយប្រឌិតនូវឯកសារក្លែងក្លាយ ។ ដែលបញ្ហានេះ បងប្អូនអ្នកស្តាប់នឹងអាចដឹងនូវអ្វីជាការពិតនៅក្នុងផ្លូវច្បាប់នៃតុលាការបែបអន្តរជាតិមួយ និងតុលាការដែល ឯករាជ្យមួយដែលសមនឹងទទួលយកដោយភាពយុត្តិធម៌ដែលគ្មានការគាបសង្កត់ពីរដ្ឋាភិបាលណាមួយនោះទេបាទ ! ។

**សម រង្ស៊ី :** បាទ អរគុណ ! សូមជម្រាបលា៕

# ទិវាស្វែងយល់អំពី សុខភាពសម្រាប់ ស្ត្រីអាស៊ី-អាមេរិកាំង ឆ្នាំទីប្រាំមួយ



## ថ្ងៃសៅរ៍ ទី៥ ខែមិថុនា ឆ្នាំ២០១០

### ម៉ោង ១០ ព្រឹក ដល់ ២:៣០ រសៀល

**នៅសណ្ឋាគារ Sheraton Philadelphia City Center Hotel**

**ផ្លូវ 17th & Race Streets, Philadelphia**

មិនបាច់បង់ថ្លៃ ... សិក្ខាសាលាអំពីសុខភាពស្ត្រីមានជាភាសាអាស៊ីផ្សេងៗ

មិនបាច់បង់ថ្លៃ ... សិក្ខាសាលាថ្មី សម្រាប់អ្នកនៅរស់ពីរោគមហារីក និងអ្នកមើលថែរបស់ពួកគេ

គេនឹងផ្តល់អាហារពេលថ្ងៃ

មានព័ត៌មានផ្សេងៗអំពីសហគមន៍អាស៊ី

មានគ្រឿងកំសាន្តពីសហគមន៍អាស៊ី

មានឱកាសចុះឈ្មោះថតមើលដោះ ដោយឥតបង់ថ្លៃ

THE OFFICIAL SPONSOR OF BIRTHDAYS.®

SUSAN G. KOMEN FOR THE CURE PHILADELPHIA

cancer.org | 1.800.227.2345
komenphiladelphia.org | 215.238.8900

**ក្រដាសបំពេញដើម្បីចុះឈ្មោះ** (សូមផ្ញើក្រដាសបំពេញដើម្បីចុះឈ្មោះនេះមកវិញត្រឹម ថ្ងៃសុក្រ ទី១៤ ខែឧសភា ឆ្នាំ២០១០)

ឈ្មោះ: ______________________ លេខទូរស័ព្ទ: ______________

អាស័យដ្ឋាន: ______________________ ទីក្រុង __________ រដ្ឋ: ________ ស៊ីពខូដ: __________

* សូមរើសយកភាសារបស់អ្នក និង **សិក្ខាសាលាតែមួយគត់។**

☐ ខ្មែរ ☐ ចិនម៉ង់ដារិន ☐ ចិនកាន់តូនីស

☐ គូចារ៉ាទី/ហិណ្ឌី ☐ ឥណ្ឌូណេស៊ី ☐ កូរ៉េ

☐ មេឡាយ៉ាឡាំ ☐ វៀតណាម ☐ អង់គ្លេស

ឬ

☐ *ថ្មី!!* សិក្ខាសាលានឹងផ្តល់ឲ្យតែ អ្នកនៅរស់ពីរោគមហារីក និងអ្នកមើលថែរបស់ពួកគេតែប៉ុណ្ណោះ។ (គេនឹងផ្តល់អ្នកបកប្រែភាសាឲ្យ។

សូមជំរាបយើងខ្ញុំនូវភាសារបស់អ្នក: ______________________)

**សូមផ្ញើទៅ:** Wan Ling Hung, American Cancer Society,
1626 Locust Street, Philadelphia, PA 19103

ឬ ទូរសារ (fax) ទៅ: 215.985.5406

ទូរស័ព្ទ: Hasven Lim, SEAMAAC, 215.467.0690 x28 (ខ្មែរ)

(Cambodian)

# A.B.C MONEY TRANSACTION, INC

# ក្រុមហ៊ុនផ្ញើប្រាក់ A.B.C



## តម្លៃសំរាប់ផ្ញើទៅស្រុកខ្មែរ

| | | ភ្នំពេញ | តាមខេត្ត |
|---|---|---|---|
| ផ្ញើ $100 | យកកម្រៃ | $4.50 | $5.50 |
| $200 | យកកម្រៃ | $9.00 | $11.00 |
| $300 | យកកម្រៃ | $13.50 | $16.50 |
| $500 | យកកម្រៃ | $16.00 | $17.00 |
| $1000 | យកកម្រៃ | $25.00 | $26.00 |
| $1500 | យកកម្រៃ | $35.00 | $36.00 |
| $2000 | យកកម្រៃ | $42.00 | $43.00 |
| $2200 | យកកម្រៃ | $46.00 | $47.00 |

សូមកុំភ្លេចទាក់ទងការិយាល័យក្រុមហ៊ុន ABC ដែលនៅជិតលោកអ្នក ប្រសិនបើមានបំណងចង់ផ្ញើប្រាក់ទៅស្រុកខ្មែរ ឬក៏ទូរស័ព្ទមកយើងតាម

### នៅរដ្ឋ VIRGINIA សូមទាក់ទង

**ABC MONEY TRANSATION ,INC.**
8 locations to serve you in Virginia

- 6757 Willson Blvd.-Ste.#25 Tel : 703.534.2600
- 4291 Holland Rd-Ste.#111 Tel : 757.474.9400
- 10428 Ridgefield Pkwy Tel : 804-740-2454
- 2519 W . Mercury Blvd . Tel : 757.265.6305
- 23520 Overland Dr. Tel : 703.661.6666
- 6314 Rigsby Rd. Tel : 804.288.2988
- 7252 Arlingston Blvd . Tel : 703.641.0778
- 6217 W. Broad St. Tel : 804.288.6988

**ARIZONA**
◆4215 N 19th Ave. . Tel : 602.266.6744

**GEOERGIA**
◆ 4897 Buford Hwy. Ste. 202. Tel: 770.457.7888

**ILLINOIS**
◆4871 N. Broadway . Tel :773.989.7332

**MASSACHUSETTE**
◆ 996 Dorchester Ave. Tel:617.825.9380
◆ 1365-1377 Dorchester Ave. -Ste.4,Froor 1 .Tel : 617.265.4600

**MINNESOTA**
◆ 2718 Nicollet Ave . S.- Ste. 102 B
◆ Tel : 612.871.4731
◆ 6350 Brooklyn Blvd . Tel : 763.503.3947

**NORTH CAROLINA**
◆ 3000 Central Ave. Ste . #9 . Tel : 704-532-4420

**OREGON**
◆6908 N.E. Sandy Blvd . Tel : 503.281.8088

**PHILADFELPHIA**
◆5520 . Whitaker Ave. -Unit 2 . Tel : 215.831.9794
◆571 Adams Ave . Ave.#4 . Tel : 215.342.6623

**TEXAS**
◆1818 E . Pioneer Pkwy. Ste.156 . Tel : 317.461.1461
◆2615 W . Pioneer Pkwy. Ste.136 . Tel : 214.788.2817
◆5302 E . Belknap St.- Ste.D6 . Tel : 817.831.4836
◆3538 W . Walnut St. Tel : 972.272.2253
◆11205 Bellaire Blvd . Tel : 281.561.6600
◆10909 Scarsdale Blvd . Tel : 281.481.2700
◆13480 Veterans Memorial Dr.-Ste. F2. Tel: 281.587.0807

**WASHINTON STATE**
◆766 S.38th St,. Tel : 253.475.2847
◆3818 S.Graham St.-Ste. C Tel : 206.721.2070

Office : 714-590-8740 Fax : 714-590-8776
Cell: 714-603-3509 Toll Free : 1-877-939-0110

## ក្រុមហ៊ុនទទួលផ្ញើប្រាក់ទៅកម្ពុជា

ABC ជាក្រុមហ៊ុនផ្ញើប្រាក់តែមួយគត់នៅស្រុកខ្មែរ ដែលមានការប្រគល់ប្រាក់ដល់ផ្ទះ

- ស្របច្បាប់
- រហ័សទាន់ចិត្ត
- ធានារ៉ាប់រង និងជូនប្រាក់ទៅដល់ផ្ទះ
- កំរៃផ្ញើថោកជាងកន្លែងដទៃ

### ក្រៅពីការផ្ញើប្រាក់ក្រុមហ៊ុនមានលក់

PHONE CARD និង PINLESS សំរាប់ទូរស័ព្ទទៅស្រុកខ្មែរ ដែលផលិតដោយក្រុមហ៊ុន ABC ផ្ទាល់ មានគុណភាពល្អ ហើយជាពិសេស CARD របស់យើងនឹងទុកបានរហូត មិនអស់កំណត់កាលឡើយ ( NEVER EXPIRED) ។

ត្រូវការអ្នកសហការ (AGENTS ) ជាមួយយើងទូទាំងសហរដ្ឋអាមេរិក និងបានទទួលប្រាក់ចំណូលយ៉ាងខ្ពស់ !

ព័ត៌មានបន្ថែមសូមទាក់ទង CHET THACTHER តាមទូរស័ព្ទ និងអាស័យដ្ឋានខាងក្រោម :

ABC MONEY TRANSATION, INC
12019 Garden Grove Blvd., Ste.#204
Garden Grove , CA 92843
chesterthatcher@yahoo.com


HONG KONG
SUPERMARKET
FAMER´S BEST
HONG KONG SUPERMARKET
(PA) WEEKLY PROMOTION ITEMS
លក់ចុះថ្លៃពីថ្ងៃ ០៤/២៣/១០ ដល់ ០៤/២៩/១០
ON SALE PERIOD
04.23.10 TO 04.29.10
$9.99/case
Newly Renovated.
Added new section .
Clean and Improved
management !
ទើបនឹងកែលំអរថ្មីឡើងវិញ
-បន្ថែមផ្នែកលក់ថ្មីទៀត
ហាងស្អាត ហើយបង្កើន
គុណភាពគ្រប់គ្រង
Weekly Sale
លក់ចុះថ្លៃរៀងរាល់សប្តាហ៍
$17.99/Bag
$4.99/Box
79¢/LB
99¢/EA
99¢/EA
99¢/LB
$1.79/LB
3/99¢
5/$2.00
$1.49/Bag
$2.69/Bag
$2.79/LB
$5.99/EA
$6.49/LB
571 ADAMS AVE.PHILADELPHIA,PA19120
Tel: 215-7281300 Fax: 215-728-1600
OPEN
7 DAY
8:00-9:00
• ចំណាយ $140ដុល្លារ ទទួលបានអង្ករស្រូវស ២៥ ផោន
• ចំណាយ $100ដុល្លារ ទទួលបាននូវភេសជ្ជៈ ឬទឹកញូប់មួយប្រអប់(តម្លៃ8.99)
• ចំណាយ $25 ដុល្លារទទួលបានទឹកសណ្តែកមួយដប ឬទឹកត្រីមួយដប ។

# ស្ត្រីខ្មែរដំបូងបង្អស់ដែលបានធ្វើដំណើរពីប្រទេសបារាំងមកភ្នំពេញតាមផ្លូវគោក



(តពីលេខមុន)

**ដោយ : ពិន នារីពិទូ**

ព្រះអង្គម្ចាស់ក្សត្រី ស៊ីសុវត្ថិ ស៊ីលវីយ៉ា ព្រះជន្ម ៥៦ ឆ្នាំក្នុងទឹកមុខញញឹម បានមានបន្ទូលថា បន្ទាប់ពីភៀសខ្លួនទៅនៅប្រទេសបារាំង ចាប់តាំងពីសម័យខ្មែរក្រហមអស់រយៈពេល ៣០ឆ្នាំ រហូតមកទល់ឆ្នាំ២០០៦ ព្រះអង្គម្ចាស់ក្សត្រីបានសំរេចចិត្តវិលត្រឡប់មកមាតុប្រទេស របស់ខ្លួនវិញ ដើម្បីចូលរួមចំណែកក្នុងសកម្មភាពមនុស្សធម៌ និងសង្គម ។ ក្នុងគោលបំណងស្វែងយល់នូវអារ្យធម៌របស់ប្រទេសនីមួយៗ ព្រះអង្គម្ចាស់ក្សត្រីរួមដំណើរជាមួយមិត្តភក្តិស្រីបារាំងម្នាក់ឈ្មោះ Aurélie បានសំរេចចិត្តដោយភាពអង់អាច និងប្រថុយប្រថានខ្ពស់ក្នុងការធ្វើដំណើរតាមផ្លូវគោកមកកាន់ទឹកដីសុវណ្ណភូមិដោយក្តីរីករាយ ។ គម្រោងនេះបានចំណាយអស់រយៈពេលបីខែកន្លះ ដោយឆ្លងកាត់មហាប្រទេសចំនួនដប់ ដូចជាប្រទេសស្វីស (Switzerland), ប្រទេសអាឡឺម៉ង់ (Germany) អូទ្រីស (Austria), សាធារណរដ្ឋ ឆែក (The CzechRepublic), ប្រទេសប៉ូឡូញ (Poland), ប្រទេសបេឡារូស (Belarus), ប្រទេស រុស្ស៊ី (Russia), ប្រទេសម៉ុងហ្គោលី (Mongolia, ប្រទេសចិន (China), ប្រទេសវៀតណាម (Vietnam) ។ ឆ្លងកាត់ពីតំបន់មួយទៅតំបន់មួយ ដោយកាត់តាមទីក្រុងនានា ទស្សនាជនបទ ជួរភ្នំ និងវាលខ្សាច់ជាច្រើន បានឃើញនូវទិដ្ឋភាពធម្មជាតិដ៏អស្ចារ្យ ទស្សនាវត្ថុបុរាណ ស្វែងយល់ពីវប្បធម៌ អារិយធម៌ និងប្រវត្តិសាស្ត្រខុសប្លែកគ្នារបស់ប្រទេសនីមួយៗ ព្រមទាំងបានទទួលការស្វាគមន៍ពីប្រជាជននៅទីនោះ ពិសារអាហារភេសជ្ជៈ និងបានផ្លាស់ប្តូរ បទពិសោធន៍ជាមួយគ្នាទៅវិញទៅមក ។

ដើម្បីសំរេចដល់គោលដៅដោយជោគជ័យ ព្រះអង្គម្ចាស់ក្សត្រី និងមិត្តភក្តិបានរៀបចំគម្រោងអស់រយៈពេល៦ខែមុនចេញដំណើរ និងត្រួតពិនិត្យមើលផែនទីពិភពលោកយ៉ាងជាក់លាក់ជាមុន ដើម្បីកំណត់គោលដៅតំបន់ដែលត្រូវឆ្លងកាត់ ត្រៀមឱ្យបានរួចរាល់នូវឯកសារដើម្បីឆ្លងដែន និងបានប្រឹក្សាយោបល់ពីមិត្តភក្តិដែលមានបទពិសោធន៍ក្នុងការធ្វើដំណើរពីមុន ព្រមទាំងមានការជួយឧបត្ថម្ភថវិកាពីមិត្តភក្តិបារាំងឈ្មោះ Anne Jacques និង Collineau ផងដែរ ។ មកទល់បច្ចុប្បន្ននេះ ព្រះអង្គម្ចាស់ក្សត្រីបានរួមចំណែកក្នុងចលនាមនុស្សធម៌ជាច្រើន ហើយព្រះអង្គម្ចាស់ក្សត្រីក៏ជាមាតាគំរូរបស់កូន១ផ្ទាល់ផងដែរ ។

ព្រះអង្គម្ចាស់ក្សត្រីស៊ីសុវត្ថិ ស៊ីលវីយ៉ា Sisowath Sylvia មានបទពិសោធន៍ការងារផ្នែកគណនេយ្យអស់ ២០ ឆ្នាំ នៅក្នុងប្រទេសបារាំង ជាកូនស្រីបង្កើតរបស់ព្រះអង្គម្ចាស់ស៊ីសុវត្ថិមុនីពង្ស ដែលជាអតីតនាយករដ្ឋមន្ត្រីខ្មែរក្នុងអំឡុងឆ្នាំ១៩៥០ និងអ្នកម្នាងម៉ារីយែត ។ រីឯអូរេលី Aurélie Colladen បច្ចុប្បន្នមានអាយុ៣១ឆ្នាំ បានចូលរួមក្នុងសកម្មភាពជំនួយដើម្បីអភិវឌ្ឍន៍សង្គមអស់រយៈពេលជិត៥ឆ្នាំ ព្រមទាំងបានបញ្ចប់ការងារផ្នែកការពារបរិស្ថានមិត្តរបស់ផែនដី Friends of the Earth ។ ពួកគេចូលចិត្តធ្វើដំណើរផ្សងព្រេង មុនពេលមកកាន់ប្រទេសកម្ពុជា ស៊ីលវីយ៉ា Sylvia និងអូរេលី Aurélie បានបញ្ចប់ការងារនៅប្រទេសបារាំងរួចអ្នកទាំងពីរក៏សំរេចចិត្តធ្វើដំណើរផ្លូវគោកតាមរថយន្តមកកាន់ប្រទេសកម្ពុជា ដោយត្រៀមដំណើរច្រើនខែ ដើម្បីឱ្យមានសុវត្ថិភាពគ្រប់គ្រាន់ ។ ក្នុងការត្រៀមលក្ខណៈជាមុន ស៊ីលវីយ៉ា Sylvia និងអូរេលី Aurélie រួមទាំងមិត្តភ័ក្រ្តបានត្រួតពិនិត្យមើលតួរថយន្តយ៉ាងយកចិត្តទុកដាក់ និងត្រៀមនូវប្រអប់គ្រឿងបន្លាស់ផ្ទុកនៅលើដំបូលរថយន្តមានដូចជា អាគុយ តំរងខ្យល់ អំពូលភ្លើង ឧបករណ៍ត្រៀមនៅពេលឡានអស់អាគុយ កង់ឡាន បំពាក់ចង្វាក់សំរាប់រត់លើផ្លូវដែលមានព្រិលធ្លាក់ខ្លាំង ធុងផ្ទុកប្រេងឥន្ធនៈ ព្រមទាំងគ្រឿងបន្លាស់ផ្សេងទៀតដែលងាយស្រួលក្នុងការរកគ្រឿងថ្មីមកជំនួស និងធន់ក្នុងការបន្លាស់ទី ។ អ្នកទាំងពីរក៏បានរួមគ្នាសរសេរឈ្មោះមិត្តភ័ក្រ្តជាច្រើនដែលបានជួយជ្រោមជ្រែងដំណើរដ៏មហិមានេះដាក់លើប្រអប់នៃដំបូលរថយន្តក្នុងបំណងអរគុណយ៉ាងខ្លាំងដល់មិត្តភ័ក្រ្តទាំងនោះ ។

អស់រយៈពេល២សប្តាហ៍នៃដើមខែសីហា ឆ្នាំ ២០០៦ អ្នកទាំងពីរបានធ្វើដំណើរឆ្លងកាត់ទ្វីបអឺរ៉ុបខាងលិចទៅអឺរ៉ុបខាងកើត ឆ្លងកាត់ក្រុងបន្តបន្ទាប់ដូចជា Zurich, Munich, Salzburg, Prague, Warsaw ជាមួយរថយន្តហ្ស៊ីបដែលមានរូបថតភ្ជាប់ជាមួយនេះ ។ Sylvia nig Aurélie បានពិព័រណ៌នាថា " ពួកយើងបានចាកចេញពីប្រទេសបារាំងតាំងពីព្រឹកម្សិលថ្ងៃទី០១ ខែសីហា ឆ្នាំ២០០៦) ធ្វើឱ្យអារម្មណ៍នឹកគិតអាឡោះអាល័យដល់ក្រុមគ្រួសារ និងមិត្តភ័ក្រ្តយ៉ាងខ្លាំង ។

នៅថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ពួកយើងបានធ្វើដំណើរឆ្លងកាត់ប្រទេសស្វីស តាមទីក្រុងហ្សូរិច Zurich ដោយមានភ្លៀង នាពេលយប់ ហើយក៏បានបោះជំរំនៅទីនោះ ។ ប្រទេសស្វីសសំបូរភ្នំណាស់ទោះជានៅរដូវក្តៅ នៅលើកំពូលភ្នំតែងមានព្រិលកកធ្លាក់ជាប្រចាំ Sylvia ក៏បានឆ្លៀតទៅចូលរួមលេងកីឡាស្គីជាមួយអេដវីឌ Edwige និងអ៊ីសាបែល Isabelle ព្រមទាំងធ្វើដំណើរកំសាន្តតាមមាត់បឹង បរិភោគអាហារ និងស្រាបៀ ។ ទីក្រុងហ្សូរិច Zurich ជាទីក្រុងដ៏ធំមួយនៃប្រទេសស្វីស Switzerland ដែលមានប្រជាជនប្រមាណ ៣៦៤.៥០០នាក់ ហ្សូរិច Zurich មានបឹងដ៏ធំមួយហូរប្រសព្វជាមួយទន្លេលីមាត Limmat ភាគខាងជើងនៃប្រទេសស្វីស Switzerland ។

នៅថ្ងៃទី០៤ ខែសីហា ឆ្នាំ២០០៦ ពួកយើងបានធ្វើដំណើរឆ្លងកាត់ទីក្រុង Salzburg ដែលមានចំងាយពីទីក្រុងមុយនិច Munich ពីរទៅបីម៉ោង ។ Salzburg ជាទីក្រុងដ៏ស្រស់ស្អាតក្នុងការដើរលំហែរកាយ ។ រដូវនេះភ្លៀងតែងធ្លាក់ជាលំដាប់ នាំឱ្យពួកយើងបានភ្លក់រស់ជាតិស្រាបៀរក្នុងស្រុកទៀត ។ Salzburg ជាទីក្រុងដ៏ធំលំដាប់ទី៤របស់ប្រទេស Autria ដែលល្បីនៅលើពិភពលោកខាងផ្នែកស្ថាបត្យកម្មប្លែកៗ ។ Salzburg ជាទីក្រុងដែលទទួល បានការអភិរក្សយ៉ាងខ្លាំង ហើយត្រូវបានចុះបញ្ជីក្នុងបេតិកភ័ណ្ឌពិភពលោកនៃអង្គប្រជាជាតិ UNESCO នៅឆ្នាំ ១៩៩៧ ។ Salzburg ស្ថិតនៅភាគខាងជើងជួរភ្នំអ័ល្បនៃទ្វីបអឺរ៉ុប មានចំងាយ១៥០គីឡូម៉ែត្រភាគខាងកើតនៃទីក្រុងមុយនិច Munich ប្រទេសអាឡឺម៉ង់ ។

នៅថ្ងៃទី០៥ ខែសីហា ឆ្នាំ២០០៦ថ្ងៃនេះពួកយើងបន្តដំណើរឆ្ពោះទៅទីក្រុងមុយនិច Munich ហើយក៏បានទទួលសារពីមិត្តភ័ក្រ្តឈ្មោះ កាមែន Carmen ដែលរស់នៅទីនោះ ។ នាពេលល្ងាចពួកយើងបានភ្លក់រស់ជាតិស្រាបៀរ ដែលជាជំនាញរបស់ពួកស្វីស និងស្តាប់ការប្រគំតន្ត្រី Bavarian ។ មិត្ត Carmen និង Maik បានស្វាគមន៍ពួកយើងយ៉ាងកក់ក្តៅ ប៉ុន្តែទីក្រុងមុយនិច Munich ពោរពេញទៅដោយភ្លៀងក្នុងរដូវនេះ ។ យើងឆ្លងកាត់ទីប្រជុំជន ដែលសំបូរដោយរូបសំណាកស្តេចតោថ្មជាច្រើន និងស្រស់ស្រូបអាហារពេលល្ងាចក្នុងភោជនីយដ្ឋាននានា ។

មុយនិច Munich ជាទីក្រុងដ៏ធំលំដាប់ទីបីរបស់ប្រទេសអាឡឺម៉ង់ បន្ទាប់ពីរាជធានីប៊ែឡាំង Berlin និង ហែមប៊ើក Hamburg ។

ថ្ងៃទី០៥ ទី០៦ និង ទី០៧ ខែសីហា ឆ្នាំ២០០៦: ពួកយើងបានឆ្លងមកដល់ប្រទេសឆេកូស្លូវ៉ាគី ហៅសាធារណៈរដ្ឋឆែក ។ ជាថ្ងៃដំបូងនៅទីក្រុងប្រាគ Prague ដែលមានចំងាយផ្លូវ៣០០គីឡូម៉ែត្រ បើកបរអស់រយៈពេល៦ម៉ោង ។ ពួកយើងបានឈប់សំរាកនៅសណ្ឋាគារនាទីប្រជុំជន រួចធ្វើដំណើរដោយថ្មើជើងលើផ្លូវក្រួសដែលប្រកបដោយសំណង់បែបបុរាណលាបពណ៌យ៉ាងប្រណិត ។ ចុងក្រោយក៏ឈប់នៅហាងភេសជ្ជៈ Czech pub ។ ថ្ងៃទីពីរពួកយើងធ្វើដំណើរតាមមេត្រូ ដើម្បីទៅទស្សនាប្រាសាទប្រាគ Prague នៃរដ្ឋធានីឆេកូស្លូវ៉ាគី ។ ទីនោះមានមនុស្សម្នាជាច្រើន **(មានតទៅលេខក្រោយ)**





NEW PHNOM PENH RESTAURANT

○ មីបំពងគ្រឿងសមុទ្រ ○ គុយទាវគោក -គុយទាវសាច់គោ
○ ផាត់ថៃ ○ ឡុកឡាក់ ○ មាន់ឆាខ្ញី
○ បាយសាច់ជ្រូកអាំង ○ មីកន្ដាំងសាច់គោ ○ បាយឆាសាច់គ្រប់មុខ



TEL.(215) 389-2122

2301 South. 7th Street. Philadelphia, PA 19148
( 7th & Wolf)

Sav-Mor PHARMACY Tel: 215-467-1220

ឱសថស្ថានខ្មែរ

Sav-Mor PHARMACY
Sam EA R.Ph.
2232 S. 7th St. (7th & Wolf) Philadelphia, Pa 19148
Tel: 215.467.1220 Fax: 215.467.1447



បំរើលោកអ្នកដោយមិត្តភាព និងរាក់ទាក់

▸▸ Sav-Mor គឺជាឱសថស្ថានបំរើ ការចែកចាយថ្នាំ ហើយអាចពន្យល់ពីរបៀបប្រើប្រាស់ថ្នាំ តាមវេជ្ជបញ្ជាជាភាសាខ្មែរបាន
▸▸ យើងទទួលយកនូវ MEDICARE MEDICAID និង INSURANCES ជាច្រើនទៀតផង យើងមានលក់កាត សំរាប់ទូរស័ព្ទទៅស្រុកខ្មែរ ឬទៅអន្តរជាតិ

* Accept most insurance plans including Medicare & Medicaid
* Easy Prescription transfer
* Inside. Prepaid phone card. Call Cambodia.

តមកទំព័រទី ០១

# ថ្ងៃ ១៧ មេសា ១៩៧៥...

ទោះជាមានកម្លាំងទប់ស្កាត់ពីរដ្ឋាភិបាលខ្មែរបង្អាក់ដំណើរយុត្តិធម៌ជូនពលរដ្ឋខ្មែរ ក៏នៅមានអ្នកពុះពារឧបសគ្គ ពុះពារការភ័យខ្លាច បាននាំគ្នាមកដាក់ពាក្យបណ្តឹងរាប់រយរាប់ពាន់នាក់ពីគ្រប់ទិសទី មានទាំងពលរដ្ឋខ្មែរ នៅសហរដ្ឋអាមេរិកផងដែរ ។ សាក្សីដែលនៅសល់ទាំងនោះ មិនត្រឹមតែទាមទារយុត្តិធម៌ទៅលើអតីតមេដឹកនាំខ្មែរក្រហម កុមប៉ុល ពត តែប៉ុណ្ណោះទេ ពួកគេបានទាមទារឱ្យអ្នកទទួលខុសត្រូវឯទៀតៗនៃក្រុមកុម្មុយនិស្តយៀកមិញផងដែរ ដែលនៅអំឡុងពេលពាឆ្នាំ៨ខែនៃរបបកុម្មុយនិស្ត កម្ពុជាប្រជាធិបតេយ្យ ក៏មានវត្តមាននៅកម្ពុជា ជាមេបដិវត្តដែរ ។ នៅមានការទាមទារឱ្យបរទេស យួន និង ចិន ដែលជាឧបជ្ឈាយ៍នៃរបបកុម្មុយនិស្តខ្មែរទាំងពីរមានទាំងការទាមទារយកព្រះនាមសម្តេចនរោត្តមសីហនុមកឆ្លើយសំនួររបស់តុលាការផងដែរ ។ ពលរដ្ឋខ្មែរជាសាក្សីនៃឧក្រិដ្ឋកម្មសម្លាប់រង្គាលបានចង្អុលមុខឃាតករ តែការរារាំងដ៏មានអំណាច បានលើកខែលមកហើយ តើសហគមន៍អន្តរជាតិ ដែលធ្លាប់តែមានជោគជ័យច្រើនសារមកហើយ ដូចជារបប ហ៊ីត្លែ, របបមេឡូសូវិក, របប រូវតដា អាហ្វ្រិកខាងត្បូង... នឹងអាចបញ្ចេញស្នាដៃថ្មីទៀតនៅកម្ពុជាបានដែរឬទេ ?

អ្នកឯកទេស និងអ្នកស្រាវជ្រាវលើរបបខ្មែរក្រហម បានសរសេរសៀវភៅផ្សព្វផ្សាយពេញពិភពលោក ជាច្រើនភាសាបង្ហាញភស្តុតាងសក្ខីកម្ម ដែលក្រុមខ្មែរក្រហមខ្លួនឯង ពុំដែលប្រកែកបដិសេធចំពោះភស្តុតាងទាំងនោះទេ... ដូច្នេះហេតុអ្វីក៏ខ្មែរក្រហមកុហក ? ហេតុអ្វីក៏រដ្ឋាភិបាលភ្នំពេញរារាំង? ចំណុចខ្មៅមានច្រើន តើខ្មែរអាចមានអាវុធសម្រាប់ដោះស្រាយបញ្ហាដោយខ្លួនឯង ដើម្បីជាតិឯងបានដែរឬទេ ?



តុលាការអន្តរជាតិបង្កើតឡើងនៅក្នុងក្របខណ្ឌ ខ្មែរ- អ៊ុន តាក់បានបង្កើតឡើងសំរាប់រំដោះខ្មែរឱ្យឯករាជ្យ-ការបោះឆ្នោតឆ្នាំ ១៩៩៣ គឺឱ្យខ្មែរប្រើឆន្ទៈ ខ្លួនឯងសំរាប់គ្រប់គ្រង់ជាតិខ្លួនឯង... ក៏ប៉ុន្តែនៅកម្ពុជាអំណាចនៅក្នុងកណ្តាប់ដៃនៃមនុស្សភាគតិច ហើយមិនឯករាជ្យពីបរទេស- នៅកម្ពុជាដដែលនោះ វប្បធម៌នៃការប្រើអ្នកចេះនៃអ្នកបរិច្ចាកដើម្បីជាតិពុំបានត្រូវបណ្តុះទេ... ម្លោះហើយអ្នកដឹកនាំកម្ពុជាពុំបានប្រើអាវុធនោះសម្រាប់ដោះខ្លួនទេ នេះជាវាស្នាដ៏អភ័ព្វនៃជនកម្ពុជា ដែលសាមសិបប្រាំហើយ នៅមិនដឹងថា នរណាដែលសម្លាប់រង្គាលលើគ្រួសារខ្លួន ។

គ្មានការកក់ក្តៅ ដោយគ្មានយុត្តិធម៌ គ្មានការពិតរស់នៅក្នុងភាពភ័យខ្លាចចំពោះអតីតកាល កម្ពុជាកំពុងតែបារម្ភថា ទៅអនាគត ថ្ងៃ ១៧ មេសា អាចនឹងកើតឡើងម្តងទៀតបានយ៉ាងជាក់ស្តែង ៕












# អាថ៌កំបាំង និងសិល្បៈនៃជីវិត
# SECRET AND ART OF LIVING



***(តមកពីលេខមុន)***

**រៀបរៀងដោយ**
**លោក ម៉ៅ ច័ន្ទសំណុំ**

●●●គួរកត់សំគាល់ថា សព្វថ្ងៃអ្នកប្រាជ្ញជាច្រើន កំពុងចាប់ផ្តើមសិក្សា បាតុភូតកុងស្បនិសនេះ ក្នុងក្របខណ្ឌវិទ្យាសាស្ត្រមួយថ្មីស្រឡាង ដែលភាសាអង់គ្លេសហៅថា Quantum physics, Quantum theoty ។ គេបានអះអាងថា ទំរង់វិទ្យាសាស្ត្របូរាណ បានវិភាគសិក្សាតែលើវត្ថុ ឬបាតុភូតនៅក្រៅដូចជា ធម្មជាតិ ជុំវិញរូបរាងកាយមនុស្ស គេពុំបានគិតគូររាប់បញ្ចូលកត្តាកុងស្បនិស ទៅជាមួយផងទេ ។ អ្នកប្រាជ្ញនៃវិទ្យាសាស្ត្រទំនើបខ្លះបានអះអាងថា Digital sciences វិទ្យាសាស្ត្រទាក់ទំនងនឹងកុំព្យូទ័រ និងអិនធឺណែតជាឧទាហរណ៍ នៃបាតុភូតកុងស្បនិសនេះឯង ។ មុខវិជ្ជាមួយចំនួនដែលយើងរៀន ៣០ឆ្នាំមុន បាននិងកំពុងក្លាយទៅជាការហួសសម័យជាមួយនឹងការរកឃើញថ្មីៗនេះ ។

អ្នកប្រាជ្ញព្រហ្មញ្ញសាសនា បានបែងចែកកុង-ស្បនិស ដែលឋិតក្នុងខ្លួនមនុស្សជា៤ប្រភេទ តាមដំណើរស់នៅរបស់យើង :

-ទី១ : កុងស្បនិសពេលដឹងខ្លួនក្នុងភាសាអង់គ្លេសហៅថា Waking state ។

-ទី២ : កុងស្បនិសពេលយល់សប្តិ Dreaming state

-ទី៣: កុងស្បនិសពេលដេកលក់ស្កប់ស្កល់ Deep sleep

-ទី៤ : កុងស្បនិសបរិសុទ្ធ Pure consciousness ក្នុងភាសាសំស្ក្រឹតគេហៅថា TURIYA ។

ខ្ញុំសូមអធិប្បាយរាយលំអិតលក្ខណៈពិសេសនៃប្រភេទនីមួយៗ និងទំនាក់ទំនងរវាងកុងស្បនិសទាំង ៤ប្រភេទនេះ ឆ្លុះបញ្ចាំងតាមការរស់នៅធម្មតារបស់មនុស្សយើងម្នាក់ៗ ដូចតទៅ :

**ទី១. កុងស្បនិសពេលដឹងខ្លួន Waking state :**

ប្រភេទកុស្បនិសនេះ ចាប់ផ្តើមពីពេលមនុស្សយើងភ្ញាក់ពីដេក រហូតដល់ពេលទ្រឡប់ចូលដេកវិញ។ ពេលនេះមនុស្សដឹងខ្លួន ទទួលអារម្មណ៍ពីក្រៅតាមរយៈ វិញ្ញាណទាំង៥ ភ្នែក ត្រចៀក ច្រមុះ អណ្តាត ស្បែក ។ ដំណើរចលនាខួរក្បាល Mental activities ប្រព្រឹត្តទៅយ៉ាងសកម្ម ។ យើងពិសោធន៍ឃើញ គំនិត thought, វេទនា censation, ទស្សនាទាន conception, ប្រតិកម្ម Reaction, ការរំជួលចិត្ត emotion, ការចងចាំ memory, ប្រាជ្ញា intelligence ។ល។ មនុស្សធ្វើការងារសព្វយ៉ាងដូចជា បើកឡាន អានកាសែត រៀនមុខវិជ្ជា គិតពិចារណា សំដែងនូវការសប្បាយរីករាយ កំហឹង ទុក្ខព្រួយ ច្រណែន ។ល។ ក្នុងផ្នែកនេះ ។

**(ក) លំហូរគំនិត Flow of thoughts :**

បើលោកអ្នកពិនិត្យក្នុងខ្លួនឯង ក្នុងរយៈពេលមួយម៉ោង តើឃើញមានគំនិតប៉ុន្មាន ឆ្លងកាត់ខួរក្បាលដ៏តូចនេះ ? ម្តងគិតទៅស្រុកខ្មែរ អំពីផ្ទះ អំពីកូនគ្រួសារ សុខភាពខ្លួនឯង រឿងរ៉ាវពីអតីតកាល រឿងមុខរបររកទទួលទាន ។ល។ គំនិតមួយលេចឡើង ហើយរលាយបាត់ទៅ គំនិតមួយទៀតងើបឡើងមក ហើយរលាយបាត់ទៅទៀត ជាបន្តបន្ទាប់ ។ គឺគំនិតនេះហើយ ដែលបូរាណតែងប្រើពាក្យថា "ចិត្តមនុស្សកក្រើករំពើកដូចទឹករលក" ឬថា "ចិត្តមនុស្សដូចសត្វស្វា ដែលតែងហក់លោតពីមែកមួយទៅមែកមួយ គ្មានឈប់ឈរឡើយ" ម្យ៉ាងទៀតគួរកត់សំគាល់ថា ចរន្តគំនិតនេះហូរពីក្នុងមកដោយឯកឯងប្រៀបដូចទឹកអណ្តូងផុះឡើងពីក្នុងដីមកគ្មានរីងហួត ។ យើងជាម្ចាស់ខ្លួនគ្មានសិទ្ធិទប់ស្កាត់ ឬបិទបើកវាបានឡើយ។ ជាទូទៅយើងជាម្ចាស់ខ្លួនពុំបានទឹកនាដល់ចរន្តនេះឡើយ យើងហាក់មានអារម្មណ៍ថា គ្មានបានគិតទៅណាទេ "មើលចុះខួរក្បាលខ្ញុំស្ងប់ស្ងាត់ល្អណាស់!!!"។ ធាតុពិតមនុស្សយើងត្រូវសណ្តំ Be hypnotized ដោយប្រព័ន្ធចរន្តគំនិតនេះប្រៀបដូចជា យើងជិះលើរថភ្លើង ដែលកំពុងតែបើកលឿនទៅមុខ យើងមានអារម្មណ៍ថាយើងនៅនឹងថ្កល់ ។

**(ខ) តើចរន្តគំនិតនេះចេញពីណាមក? តើយើងជាម្ចាស់ខ្លួន ជាអ្នកបង្កើត ឬយ៉ាងណា?**

មនុស្សយើងកើតមកពុំដឹងអ្វីទាំងអស់ គ្មានអ្វីទាំងអស់ក្នុងខ្លួន ប្រៀបដូចក្រដាសសស្អាត ។ តាមរយៈមាតាបិតា ឬបងប្អូន យើងចាប់ផ្តើមរៀនដើរ និយាយ ហូប ច្រៀង គូរ ស្តាប់ ស្រឡាញ់ ចូលចិត្ត ។ល។ លុះធំដឹងក្តីល្មមទៅសាលា យើងរៀនវិជ្ជាគ្រប់ពីសាលារៀន សរសេរ អាន គិតពិចារណា ដោះស្រាយចំណោទ។ ផុតពីនេះទៅយើងឆ្លងទៅមួយដំណាក់ទៀត ពោលគឺរស់នៅក្នុងសង្គមនោះ ការរៀនសូត្រក៏ពុំទាន់ចប់ ហើយត្រូវបន្តរៀនអំពីច្បាប់ទំលាប់ ប្រពៃណី វប្បធម៌ អារ្យធម៌ ។ល។ និង។ល។ យើងក៏មានអត្តសញ្ញាណថា ជាជនជាតិ ខ្មែរ ចិន ថៃ បារាំង ។ល។ មជ្ឈដ្ឋានរស់នៅវាបានកំណត់ បុគ្គលិកលក្ខណៈយើងម្នាក់ៗ។ ការរៀបរាប់មកដល់ចំណុចនេះ យើងអាចប្រៀបធៀបតួមនុស្សនេះ ទៅនឹងម៉ាស៊ីនថតសំឡេង។ ម៉ាស៊ីននេះ បើយើងថតបញ្ចូលអ្វី វានឹងបញ្ចេញរបស់ទាំងនោះ ដូចបេះបិតមកវិញ ។ មនុស្សយើងអាចប្រៀបម្យ៉ាងទៀតទៅនឹងម៉ាស៊ីនកំព្យូទ័រ ដែលធ្វើសកម្មភាពតាមតែប្រូក្រាម ដែលគេបញ្ចូលពីមុនមក។ យើងម្នាក់ៗ ថតចម្លងចំណេះវិជ្ជា ការពិសោធន៍ល្អ ឬអាក្រក់ ព្រឹត្តិការណ៍ផ្សេងៗពីសង្គមមជ្ឈដ្ឋានរស់នៅ បញ្ចូលទៅក្នុងបន្ទប់មេម៉ូរី Memory ឬកន្លែងចងចាំ (តាម"ភាសាសំស្ក្រឹតហៅថា Samskara-the root imopression of the past deeds or impression in the subconscious mind) ដែលឋិតនៅក្នុងខ្លួនយើងគ្រប់រូប។ គឺបន្ទប់មេម៉ូរីនេះហើយ ដែលបង្កើតបានជាឃ្លាំងព័ត៌មានសំរាប់យើងប្រើប្រាស់ បញ្ចេញមកក្រៅជាលំហូរគំនិតគ្មានរីងស្ងួត បង្កើតបានជាប្រព័ន្ធឡូសិក Logic សំរាប់ធ្វើកិច្ចការសព្វយ៉ាង បំរើជីវភាពរស់នៅ ។ ប្រព័ន្ធឡូសិកនេះ មានដំណើរឆ្លើយឆ្លងពីក្នុងមកក្រៅ ឬពីក្រៅមកក្នុងជា **ស្វ័យប្រវត្តិ** ***(នៅមានតលេខក្រោយ)***


**ANGKOR AUTO SERVICE, INC.**

**ហាងជួសជុលរថយន្ត "អង្គរ"**

4835 N. 16th Street.
Philadelphia, Pa 19141

Tel : (215) 455-7810
Ricky : (215) 485-1425

Specializing in Body Kit and Custom Paint

**ជំនាញខាងជួសជុលតួរថយន្ត**
**និងបាញ់ថ្នាំដាក់ក្បាច់តាមបំណងភ្ញៀវ**

RICKY
Hand Ph.: Ricky 215-485-1425

មានបទពិសោធន៍២០ ឆ្នាំ
ជាជាងរថយន្តមានសញ្ញាប័ត្រ
វាយតម្លៃការងារដោយឥតយកថ្លៃ
ហើយយើងជួយសន្សំប្រាក់តម្លៃ
បន្ថយរបស់អិនស្វិន បានផង
យើងផ្តល់សេវាគ្រប់យ៉ាង :

-State inspection
-Insurance Claims
-Auto Glass Repairs
-Auto Frame Repairs
-Custom Painting
-Auto A/C









**បើកពីម៉ោង ៩ ព្រឹក**
**ដល់ម៉ោង៥ល្ងាច ពីថ្ងៃ**
**ចន្ទ ដល់ ថ្ងៃ សៅរ៍**

**ចុះតម្លៃជូន 10 % បើបង្ហាញប័ណ្ណពាណិជ្ជកម្មនេះ**

**New World Travel II**

**ញូវលត្រាវែលធូ**

Specialized in Selling Flight Tickets
For National and International

ជំនាញខាងលក់សំបុត្រយន្តហោះសំរាប់ក្នុងប្រទេស និងអន្តរជាតិ យើងតំណាងឱ្យក្រុមហ៊ុន ចិន កូរ៉េ កាថេ ។ល។ ធ្វើលិខិត Re-Entry Permit ប្រញាប់ជូនបានទិញសំបុត្រជិះនាវាសមុទ្រ សណ្ឋាគារ ឬជួលឡាន សំបុត្រយន្តហោះទៅច្រើនប្រទេសក្នុងតម្លៃទាបបំផុត ។

Represented Several of Company such as China, Korea, Cathay etc.,
Offer Rush Re-Entry Permit
Reserve Cruise, Hotels and Car Rentals
Best Price Air Ticket for Many Destinations

600 Washington Ave Suite #8
Philadelphia, Pa 19147
Tel: (215) 463-1257
Fax: (215) 463-2036

# រងគ្រោះព្រោះតែជួយគេ



ដោយ : អ៊ុំមឿម

ហ្វីឡាដែលហ្វៀ : យុវជនខ្មែរ-អាមេរិកាំងម្នាក់ត្រូវបានស្លាប់ និងបីនាក់ផ្សេងទៀតត្រូវបានរបួសដោយសារការបាញ់ប្រហារដ៏សាហាវយង់ឃ្នងមួយពីសំណាក់ឃាតករមកខ្លាចច្បាប់ ដែលមានឈាមជ័រជាខ្មែរដូចគ្នា នាព្រឹកថ្ងៃសៅរ៍ ទី០៣ ខែមេសាកន្លងមកនេះ នៅចំកណ្ដាលទីក្រុងហ្វីឡា-ដែលហ្វៀ ផ្នែកខាងត្បូង លើដងវិថីលេខ 8 st Mo-yamenshig ព្រោះដោយសារតែជម្លោះបន្តិចបន្តួច ។

ជនរងគ្រោះដែលបាត់បង់ជីវិត ដោយសារការបាញ់ប្រហារក្នុងហេតុការណ៍នោះ ឈ្មោះ រ៉េន ទីតុន អាយុ ២៣ឆ្នាំ មានទីលំនៅស្ថិត 10 st Jackson នាទីក្រុងហ្វីឡាដែលហ្វៀខាងត្បូង ។ ជនរងគ្រោះបានស្លាប់នៅកន្លែងកើតហេតុវេលាម៉ោង ៥ : ៣០ ព្រឹក ។

អ្នកស្រី ឆន ថន អាយុ ៤៤ ឆ្នាំ ដែលត្រូវជាម្ដាយជនរងគ្រោះបានឱ្យ "ខ្មែរប៉ុស្តិ៍" ដឹងថា ការស្លាប់កូនរបស់អ្នកស្រី គឺមិនមែនជារឿងខ្លួនឯងឡើយ តែនោះជារឿងការទៅជួយអន្តរាគមន៍, ឃាត់ឃាំងកុំឱ្យគេឈ្លោះគ្នាតែប៉ុណ្ណោះ ហើយខ្មាន់កាំភ្លើងក៏ជាកូនខ្មែរ តែមិនមែនជាមិត្តភ័ក្រ្ត និងមិនដែលធ្លាប់ស្គាល់គ្នាពីមុនដែរ ។ អ្នកស្រី ឆន ថន បានបន្តថា : កូនប្រុសរបស់គាត់ជាមនុស្សស្លូតបូត, សុភាពរាបសារ, មិនចេះផឹកស៊ី និងមិនដែលដើរចោលផ្ទះឡើយ ហើយក៏មិនធ្លាប់មានទំនាស់ជាមួយអ្នកផ្សេងឡើយ ។ ចំណែកឯអ្នករងរបួសបីនាក់ទៀត ដែលជាស្នាដៃរបស់ខ្មាន់កាំភ្លើងតែមួយ ត្រូវបានអ្នកស្រី ឆន ថន បញ្ជាក់ថា គឺសុទ្ធតែជាកូនក្មួយរបស់អ្នកស្រីទាំងអស់ ដោយក្នុងចំនួននោះ មានម្នាក់រងរបួសស្រាល និងពីរនាក់





ទៀតរបួសធ្ងន់ ។

ចំណែកឯដើមចមដែលបណ្ដាលឱ្យមានការបាញ់ប្រហារគ្នាយ៉ាងសាហាវបែបនេះ ពុំត្រូវអ្នកស្រី ឆន ថន ដែលជាម្ដាយជនរងគ្រោះបញ្ជាក់ឱ្យបានច្បាស់លាស់នៅឡើយ ហើយ "ខ្មែរប៉ុស្តិ៍" នឹងខិតខំតាមដានចំពោះករណីនេះជាបន្តទៀត ។

នៅចំពោះមុខអ្នកយកព័ត៌មាន "ខ្មែរប៉ុស្តិ៍" អ្នកស្រី ថន អ្នកស្រីបានបង្ហាញនូវទឹកមុខស្រពោន ជូតទឹកភ្នែកដោយក្ដីក្ដុកក្ដួលអួលណែន ហើយបានថ្លែងដោយសម្លេងខ្សាវៗថា : " អ្នកស្រីមិនសុខចិត្តឡើយចំពោះការស្លាប់របស់កូនប្រុសគាត់ ហើយអ្នកស្រីនឹងបន្តសហការណ៍ជាមួយសមត្ថកិច្ចក្នុងការរកមុខឃាតករមកផ្ដន្ទាទោសតាមផ្លូវច្បាប់ឱ្យខានតែបាន ហើយប្រការដែលគួរឱ្យឈឺចាប់ទៀតនោះ ព្រោះអ្នករបួសបីនាក់ផ្សេងទៀត គឺសុទ្ធតែជាកូនក្មួយរបស់អ្នកស្រីទាំងអស់ ។

តាមរយៈសារព័ត៌មាន "ខ្មែរប៉ុស្តិ៍" អ្នកស្រី ឆន ថន បានធ្វើការផ្ដាំផ្ញើរដល់បងប្អូន កូនខ្មែរទាំងអស់ថា : "សូមបង្កើននូវការប្រុងប្រយ័ត្នខ្ពស់បំផុត កុំឆាប់ជឿទុកចិត្តអ្នកដទៃ និងកុំចេញមុខជួយឈឺឆ្អាលចំពោះរឿងរបស់អ្នកផ្សេងខ្លាំងពេក ព្រោះខ្លាចកើតរឿងចៃដន្យដូចកូនអ្នកស្រីជាដើម..." ។

សពរបស់យុវជន រ៉េន ទីតុន ត្រូវបានក្រុមគ្រួសារនាំយកមកធ្វើបុណ្យតាមប្រពៃណីជាតិនៅឯវត្ត "ព្រះពុទ្ធវង្សី " នារាត្រីថ្ងៃសៅរ៍ ទី៩ ខែមេសាកន្លងមកនេះ ហើយត្រូវបានបូជានៅរសៀលថ្ងៃបន្ទាប់ ។

គួររំលឹកផងដែរថា : ហ្វីឡាដែលហ្វៀ ជាទីក្រុងចំណាស់មួយដែលចម្រុះទៅដោយពហុជាតិសាសន៍យ៉ាងណែនណាន់តាន់តាប់ ហើយក៏ជាក្រុងដែលល្បីល្បាញខាងឃាតកម្ម, ចោរកម្ម, អ្នកសេព និងជួញដូរគ្រឿងញៀន... ។ ដោយគ្រាន់តែរយៈពេល១ខែសោះ មានកូនខ្មែរពីរនាក់ត្រូវបានសម្លាប់ និងមួយចំនួនផ្សេងទៀតត្រូវរបួស ។ ក៏ប៉ុន្តែហ្វីឡាដែលហ្វៀជាទីក្រុងមួយដែលត្រូវបានចារទុកប្រវត្តិសាស្រ្តអាមេរិក ដែលអាចធ្វើឱ្យសហរដ្ឋអាមេរិក បោះជំហានរហូតមកដល់បច្ចុប្បន្ននេះ ហើយក៏ជាក្រុងដែលសម្បូរណ៍ទៅដោយការងារគ្រប់ជំពូក ។ ទោះបីជាអ្នកគ្មានសិទ្ធិពេញលេញក្នុងការរស់នៅលើទឹកដីមហាយក្សអាមេរិកក្ដី ក៏អ្នកទាំងនោះអាចរកការងារក្រៅប្រព័ន្ធបានដោយងាយស្រួល ក្រៅពីនោះ ទឹកដីដ៏កកណែនដោយពលរដ្ឋខ្មែរជិត៣ម៉ឺននាក់មួយនេះ ក៏ជាមូលដ្ឋានដ៏សំខាន់របស់គណបក្សនយោបាយខ្មែរផងដែរ ។ រីឯវត្តអារាមព្រះពុទ្ធសាសនា, វិហារគ្រីស្ត-សាសនា សមាគមនានា និងអង្គការផ្សេងៗ ក៏បានបង្ហាញនូវវត្តមានរបស់ខ្លួនយ៉ាងស្អេកស្កះលើទឹកហ្វីឡានេះផងដែរ... ៕

## តមកទំព័រទី ០៣ ក្រុមអាវក្រហមថៃបង្កើនការ...

ចូរខំបើកភ្នែកទាំងពីរឱ្យធំឡើង មើលឱ្យឃើញច្បាស់ ហើយបើកត្រចៀកទាំងពីរឱ្យធំ ខំមើល និងស្ដាប់ឱ្យឃើញ និងឮពីសកម្មភាពមហាបាតុករក្រុមអាវលឿង រហូតដល់ក្រុមអាវក្រហមក្រហម អស់រយៈពេលជាច្រើនឆ្នាំកន្លងមកហើយ តើបានឃើញកងទ័ព និងតម្រួតសៀម បានបាញ់គ្រាប់កាំភ្លើងរះបំបែក និងបង្ក្រាបក្រុមមហាបាតុករ បណ្ដាលឱ្យស្លាប់អស់ប៉ុន្មាននាក់ហើយ បើប្រៀបធៀបមកជាមួយកងទ័ព និងនគរបាលខ្មែរ កាលពីប៉ុន្មានឆ្នាំកន្លងមកនេះ ?

នេះបញ្ជាក់បង្ហាញថា កងទ័ព និងតម្រួតសៀម គឺជាសៀមដូចគ្នាហ្វូងមហាបាតុករសៀមនោះដែរ មិនដូចគ្នាកងទ័ព នឹងនគរបាលខ្មែរ ប៉ុន្តែការបាញ់កាំភ្លើងរះទៅលើហ្វូងមហាបាតុករខ្មែរទេ ។

សរុបសេចក្ដីទៅ បញ្ហាវិបត្តិនយោបាយនៅក្នុងប្រទេសថៃ គឺជារឿងផ្ទៃក្នុងរបស់គេ រដ្ឋាភិបាលខ្មែរក្ដី ប្រជាពលរដ្ឋខ្មែរក្ដី គួរស្ថិតនៅជាអ្នកខិតខំគិតគូពង្រឹង និងពង្រីកសាមគ្គីភាព គោលជំហរ និងទឹកចិត្តក្នុងឆន្ទៈអង់អាចក្លាហានបំផុត រឹងមាំបំផុតស្វែងរកយុត្តិធម៌ គុណធម៌ សីលធម៌ ក្នុងសង្គមជាតិខ្មែរ ឱ្យកើតមានពិតប្រាកដ ទៅតាមគោលការណ៍លទ្ធិ-ប្រជាធិបតេយ្យពិតប្រាកដ គោរពច្បាប់និតិរដ្ឋពិតប្រាកដ ការពារឯករាជ្យ បូរណភាពទឹកដីពិតប្រាកដ ទើបពេលនេះប្រទេស និងប្រជាជាតិខ្មែរបានគង់វង្សរីកចំរើន លូតលាស់គ្រប់វិស័យ សុខសន្តិភាព និងសុវត្ថិភាពក្នុងសង្គមជាតិខ្មែរទាំងមូលទៅបានជានិរន្តរ៍រៀងរហូតតទៅ ៕

**រកស្ត្រីអ្នកធ្វើក្រចក**

មានបច្ចេកទេស និង Licence PA. ធ្វើការនៅ Strovsburg PA. ចម្ងាយ ១២ ម៉ោង ពីហ្វីឡា មានបន្ទប់ជូនសំរាក-ព័ត៌មានបន្ថែម ទូរស័ព្ទ 570-350-4114 ឬ 570-424-9466



# វែកមុខពពួកជនដង្កូវអាចម៍ក្នុងសង្គមខ្មែរ



•••ជាដំបូងយើងសូមសរសើរដល់សម្តេច ហ៊ុន សែន ជានាយករដ្ឋមន្ត្រីនៃប្រទេសកម្ពុជា ដែលលោកខំដើរតួយ៉ាងខ្ពង់មួយក្នុងឆាកនយោបាយបច្ចុប្បន្នអស់រយៈកាលជាងសាមសិបឆ្នាំកន្លងមកហើយ ។ ម្យ៉ាងទៀត សម្តេចបានប្រឹងខ្នះខ្នែងបំបាក់ពួកទមិឡខ្មែរក្រហម បានជោគជ័យជាស្ថាពរ។ ទន្ទឹមគ្នានោះសម្តេចក៏បានខំប្រឹងយ៉ាងសកម្មកាប់លក់ព្រៃឈើហូតកើតជាវាលស្រីស្រណោះហើយដែរ ដែលបានភោគផលរហូតដល់រាប់រយលានដុល្លារអាមេរិក ។ បច្ចុប្បន្ននេះទៀតសោតសម្តេចក៏នៅតែខំប្រឹងយ៉ាងមមាញឹក ដើម្បីស៊ីញេ(Sing)ទឹកដីខ្មែរ ឱ្យជាសម្បទានរាប់ពាន់ម៉ឺនហិកតា ក្នុងអំឡុងកៅសិបប្រាំបួនឆ្នាំឱ្យទៅដល់មហាមិត្តវៀតណាម(យួន)អ្នកភូមផងរបងជាមួយថែមទៀត ។ល។

បើយោងទៅតាមគំនិត ពាក្យសំដីលោកម៉ម សូណង់ដូ ប្រធានវិទ្យុសំបុកឃ្មុំបានមានប្រសាសន៍ថា សម្ភារៈដែលអាចមានតម្លៃទៅបានលុះត្រាតែអ្នកទទួលនោះត្រូវការ ហើយចេះយកទៅច្នៃប្រើការ លើគ្របវិស័យ ជាសារៈប្រយោជន៍សម្រាប់ខ្លួនឯងនិងជាពិសេស ចំពោះសង្គមទូទៅផង ។ យើងក៏យល់ស្រប និងគាំទ្រទទួលស្គាល់ក្នុងគំនិតនេះដែរ ព្រោះថា ដូចនៅសម័យប៉ុលពត ពួកខ្មែរក្រហមបានជម្លៀស ដេញទាំងបង្ខំឱ្យប្រជាពលរដ្ឋឃ្លាតចាកចេញពីលំនៅឋាន ភូមិ ស្រុកឱ្យទៅនៅតាមព្រៃដូចសត្វតិរច្ឆាន ។ល។ នៅក្នុងសម័យនោះយើងក៏នៅចាំមិនភ្លេចដែរថា ពួកឈ្មួញធំៗ អស់លោកធំៗ បានលះបង់ចោលប្រាក់កាសអស់រាប់ការុង រាប់បាវ ព្រមទាំងមាសពេជ្ររាប់គីឡូផងដែរ ។ បច្ចុប្បន្ននេះ លោកតាម៉ម សូណង់ដូ បានបង្កើនក្លឹប(Club) ប្រជាធិបតេយ្យដើម្បីប្រកាសអញ្ជើញអស់លោកគ្រប់គណបក្ស ប្រជារាស្ត្រគ្រប់ជាន់ថ្នាក់ ដែលជាអ្នកស្រលាញ់ ការពារលទ្ធិប្រជាធិបតេយ្យពិតប្រាកដ ឥតក្លែងបន្លំ ដែលអ្នកខ្លះដើរតួធ្វើជាដង្កូវអាចម៍ ក្នុងសង្គមខ្មែរ បំផ្លាញជាតិសាសន៍ខ្លួនឯកឥតក្រែងរអែង ហើយខំបំបាត់ពូជពង្សខ្លួនឯង និងបូរណភាពទឹកដីខ្មែរផង។

ពួកគេនេះ ចេះអរសប្បាយ ក្អាកក្អាយ ភ្លើតភ្លើន តែនឹងអំពើពុករលួយសព្វយ៉ាង ដែលស្អុយគគ្រុកលើសលាមក ឬកម្រង់អសោចន៍ទៅទៀត ឥតដែលមានព្រលឹងជាតិ ខួរក្បាលពូជខ្មែរអង្គររើសដាក់ខ្លួនបន្តិចណាសោះឡើយ ប្រៀបដូចហ្វូងត្មាតខំប្រឹងប្រចឹកប្រទាញ អូសគំរង់ ដើម្បីបំប៉នអាត្មាអញ ខំរស់តែរង្វង់គ្រួសារអញ បក្សពួកអញប៉ុណ្ណោះ ។

ដូច្នេះបន្តិចទៀតយើងនឹងឃើញ តើនរជនណាមួយ ចេះស្រលាញ់ជាតិសាសនាខ្លួនឯង (ខ្មែរ)ពិតប្រាកដឥតក្លែងក្លាយ ? ម្យ៉ាងទៀត តើវីរជនណាមួយដែលខំបន្លំខ្លួនដើរតួ បោកបញ្ឆោតប្រជារាស្ត្រខ្លួនឯង ក្បត់ឧត្តមកតិខ្លួនឯង ដោយឥតមានទឹកស្រណោះដល់ជាតិ មាតុភូមិ និងមរតកពូជខ្មែរអង្គរពូជអច្ឆរិយ ? ព្រោះក្លឹបប្រជាធិបតេយ្យរបស់ លោកម៉ម សូណង់ដូ ប្រាកដជាមានតម្លៃពិសេសអាចចេះរែងរាវរកអង្គរដើម វែកមុខពួកជនក្បត់បរទេសសម្លាប់ពូជសាសន៍ខ្លួនឯង។ មិនតែប៉ុណ្ណោះក៏ជាវិធីអាចទប់ស្កាត់ ការពារបូរណភាពទឹកដីខ្មែរ ដែលកំពុងតែធ្វើដំណើរឆ្ពោះទៅរកគ្រោះមហន្តរាយយ៉ាងគួរឱ្យព្រួយបារម្ភជាអនេក ដោយជនជាតិយួន ក៏កំពុងតែហូរចូលមកនៅក្នុងទឹកដីខ្មែរយ៉ាងច្រើនលើសលុបស្ទេកស្ទះណាស់ទៅហើយ ។ល។

តើឱ្យបងប្អូនខ្មែរដែលជាម្ចាស់ប្រទេស ម្ចាស់ទឹកដីសុខចិត្តបិទភ្នែកដេកងាប់ ធ្វើខ្វាក់ គថ្លង់បានដែរឬទេ? ឬក៏សុខចិត្តងើប បើកភ្នែកភ្ញាក់ឡើងជួយទប់ជ្រែងយ៉ាងណាដើម្បីជាតិរស់ឬទេ ?"រាស្ត្រខ្មែររលំដីខ្មែររលាយសាសន៍ខ្មែរខ្វាត់ខ្វាយ សប្បាយយួនយៀក? អូឡា! ឡា! ដោយសារលោកម្ចាស់ណាស"?

ដោយនាយភ្នែកល្បៀន (Zoom´s Eyes) ។

ផ្ទះ Duplex សំរាប់ជួល

-នៅតំបន់ Mi Airy, Philadelphia ជាន់ទី១ មាន២បន្ទប់ មាន Central Air មានម៉ាស៊ីនបោក និងហាលខោអាវ-មានធុងចោលសំរាម ដាក់ព្រំពេញបន្ទប់ មានកន្លែងដាក់ឡាន

-តម្លៃជួល $ 825/១ខែ + ថ្លៃទឹក ភ្លើង

-ទូរស័ព្ទ : 267-243-7039

អានជំនាញខាងទិញ.លក់ផ្ទះ.ពាណិជ្ជកម្ម. វិនិយោគ ហិរញ្ញវត្ថុ ឬជួល
បើកឱកាសចំពោះលោកអ្នកដែលចង់វិនិយោគ



Vinh Ho, 215-391-9516
Email: vho.realestate@consultant.com
ANCHOR Real Estate Development
320 Oregon Ave, #3B, Philadelphia, PA 19148
Specialize - Buy_Sell_Invest_Finance_Rent ...
Beginner-investors are welcomed!

Yes you can!

... get free or low-cost health insurance for your children.

- Did you lose your health insurance when you lost your job?
- Do your children have no health insurance?
- Do you wonder how you'll afford your kids' next doctor visit?

AmeriChoice
A UnitedHealth Group Company

(215) 360-9841
Leap Thach

Your children deserve to be healthy.
AmeriChoice can help.



Repro Center
怡保印刷中心
the printer you can trust
Since 1993

- Fast, Easy Print Ordering
- Premium Quality
- Low Price
- Excellent Customer Service

T: 215.271.5041 /5042
1531-33 South 7th Street
Philadelphia • PA 19147
F.: 215.271.5043 • reprocenter@usa.net

BUSINESS CARDS as low as $15



សេវាបោះពុម្ព

- តារាងម្ហូបភោជនីយដ្ឋាន
- លិខិតចម្លងគ្មានកាបូន
- កែអស័យដ្ឋាន
- ស្រោមសំបុត្រ
- ថតចម្លងពណ៌ឌីស៊ីតុល
- សេវាបញ្ជូនលិខិត
- កាតាឡុកសៀវភៅ
- ខិតប័ណ្ណបត់ជាសៀវភៅ
- ខិតប័ណ្ណលាត
- រូបផ្ទាំងស្អាតតូចៗ
- ផ្ទាំងរូបផូស្ទ័រធំៗ
- ប្រតិទិន
- ធ្វើហ្វូលឌ័រសម្រាប់ផ្សាយ
- បកប្រែ
- គូសក្រាហ្វិក
- ធ្វើត្រាមាស
- អ៊ុតលើក្រប
- ធ្វើក្រប
- ប្រតិទិន
- ប៉ាក់លើក្រណាត់ ឬសូត្រ

Services Products

Restaurant Menu
Carbonless NCR Form
Business Cards
Envelopes
Letterhead
Digital Color Copy
Mailing Services
Catalogs / Booklets
Brochures
Flyers
Postcards
Posters
Calendars
Presentation Folder
Translation
Graphic Design
Gold Foil Stamping
Laminating
Labels
Clothing Embroidery
/ Silk Screen


សួស្តីឆ្នាំថ្មី
Happy New Year
សូមអរគុណ ចំពោះភ្ញៀវទាំងអស់ដែលបាន
គាំទ្រដល់ភោជនីយដ្ឋានយើងខ្ញុំ
Kavei
ភោជនីយដ្ឋានខ្មែរ
320 OREGON AVENUE . PHILADELPHIA PA 19148 . 215-952-6688
សម្លម្ជូរយួន
នំបញ្ចុកសម្លខ្មែរ